# សង្គមក្រៅរដ្ឋាភិបាលដាក់ញត្តិជាមួយនឹងការគំរាមធ្វើបាតុកម្មបញ្ចុះតម្លៃសាំង




ក្រុមអង្គការសង្គមក្រៅរដ្ឋាភិបាលចំនួន១៨ និង ប្រជាពលរដ្ឋប្រមាណ ១០០នាក់ ពេលយកញត្តិទៅដល់មុខរដ្ឋសភា កាលពីថ្ងៃម្សិលមិញ។ រូបថត ម៉េង គីមឡុង



សង្គមក្រៅរដ្ឋាភិបាល និងពលរដ្ឋយកញត្តិទៅដាក់រដ្ឋសភាម្សិលមិញ។ រូបថត គីមឡុង

ភ្នំពេញៈ ក្រុមអង្គការសង្គមក្រៅរដាភិបាលចំនួន១៨ និងប្រជាពលរដ្ឋប្រមាណ ១០០នាក់ បានដាក់ញត្តិរួមគ្នាមួយទៅប្រធានរដ្ឋសភា កាលពីព្រឹកម្សិលមិញ ដើម្បីស្នើសុំឲ្យជួយអន្តរាគមន៍ទៅប្រមុខរដ្ឋាភិបាលឲ្យចាត់វិធានការបញ្ចុះតម្លៃប្រេងសាំងជាបន្ទាន់ជាមួយនឹងការព្រមានពីការធ្វើមហាបាតុកម្មដ៏ធំមួយ ប្រសិនបើប្រេងសាំង មិនត្រូវបានបញ្ចុះថ្លៃ ឲ្យមានតម្លៃប្រហាក់ប្រហែលទៅនឹងប្រទេសជិតខាងទេនោះ។

អង្គការសង្គមក្រៅរដាភិបាលទាំង ១៨ ដោយមានការចូលរួមគាំទ្រពីក្រុមអ្នករត់ម៉ូតូឌុប ម៉ូតូកង់បី កម្មករ កសិករ អាជីវករ និស្សិត និងមន្ត្រីរាជការប្រមាណ ១០០នាក់បានជួបជុំគ្នានៅមុខរដ្ឋសភា ដើម្បីដាក់ញត្តិ ជាមួយនឹងការថ្លែងតាមឧគ្ឃោសនស័ព្ទថា ការដំឡើងថ្លៃប្រេងសាំង គឺជាដើមចម ដែលធ្វើឲ្យទំនិញគ្រប់ប្រភេទហាក់ឡើងថ្លៃ។

លោក វន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធបានថ្លែងថា ការកើនឡើងនូវតម្លៃសាំងបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការប្រកបមុខរបរទទួលទានរបស់ប្រជាពលរដ្ឋទូទាំងប្រទេស ហើយវាក៏ជាឧបសគ្គដល់ផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។

លោកបាននិយាយ ដោយលើកបង្ហាញអំពីសន្ទស្សន៍នៃតម្លៃប្រេងឥន្ធនៈនៅកម្ពុជា ដោយប្រៀបធៀបទៅនឹងប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់អាស៊ាន ដែលក្នុងនោះសន្ទស្សន៍តម្លៃប្រេងឥន្ធនៈនៅកម្ពុជាបានកើនឡើងដល់ទៅ ១,៤៩ ដុល្លារ ក្នុងមួយលីត្រ ខណៈប្រេងសាំងនៅប្រទេសជិតខាង ដូចជាប្រទេសសៀមថ្លៃត្រឹមតែ ១,២៧ដុល្លារក្នុងមួយលីត្រ ភូមា ថ្លៃត្រឹម ១ ដុល្លារក្នុង ១លីត្រ ប្រទេសលាវ ថ្លៃត្រឹម ១,១០ដុល្លារក្នុងមួយលីត្រ ពិសេសប្រទេសយួន ដែលជាប្រទេសមហាមិត្តរបស់កម្ពុជា គឺមានតម្លៃត្រឹមតែ ១,០៥ដុល្លារ ប៉ុណ្ណោះក្នុងមួយលីត្រ។

ជាមួយគ្នានោះដែរ លោកអ៊ុំ វិសាល មន្ត្រីដោះស្រាយវិវាទការងារនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាបាននិយាយថា ការកើនឡើងនៃតម្លៃសាំងបានធ្វើឲ្យតម្លៃទំនិញសព្វសារពើ ព្រមទាំងតម្លៃដឹកជញ្ជូន និង ថ្លៃសេវាកម្មផ្សេងៗទៀតក្នុងប្រទេសកម្ពុជាកើនឡើងកាន់តែខ្ពស់។ លោកបានបន្តថា កម្មករទទួលបានប្រាក់ខែគោលត្រឹមតែ ៦១ដុល្លារ គឺមិនគ្រប់គ្រាន់សម្រាប់ការចំណាយទៅលើការហូបចុក ថ្លៃឈ្នួលផ្ទះ ទឹក ភ្លើង និងថ្លៃធ្វើដំណើរ (តាមរ៉ឺម៉ក ឬ តាមរថយន្តដឹកអ្នកដំណើរ) នោះទេ។ លោកបានថ្លែងថា៖ «ថ្លៃសាំងកាន់តែឡើងខ្ពស់ ជីវភាពកម្មករកាន់តែដុនដាប»។

ចំណែកលោក ឡុង វុទ្ធី តំណាងអ្នករត់ម៉ូតូកង់បីក្នុងទីក្រុងភ្នំពេញបាននិយាយថា ភ្ញៀវរបស់លោកស្ទើរតែលែងហ៊ានជិះម៉ូតូកង់បីរបស់លោកហើយ ចាប់តាំងពីប្រេងសាំងបានកើនឡើងពី ៥៥០០ដល់ជិត ៦០០០រៀលក្នុងមួយលីត្រដោយលោកបានតម្លើងថ្លៃដឹកជញ្ជូនដែរ។

ចំណែកលោក ខេម រ៉ា តំណាងសម្ព័ន្ធសហគមន៍កសិករកម្ពុជាបានថ្លែងថា នៅពេលតម្លៃសាំងកាន់តែថ្លៃ ប្រជាកសិករកាន់តែមានក្ដីព្រួយកង្វល់ ព្រោះតម្លៃកសិផលរបស់ពួកលោកមានតម្លៃទាបពេក។

លោក អំ សំអាត ទីប្រឹក្សាបច្ចេកទេសនៃអង្គការសិទ្ធិមនុស្សលីកាដូក៏បានចូលរួមនៅក្នុងការអំពាវនាវសុំឲ្យប្រមុខរដ្ឋាភិបាលជួយដោះស្រាយនូវវិបត្តិនៃការឡើងថ្លៃប្រេងឥន្ធនៈនេះផងដែរ ដោយលោកថ្លែងថា វិបត្តិនេះមិនគ្រាន់តែប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែវាបានធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិផងដែរ។ លោកបន្តថា៖ «រោងចក្រសហគ្រាស និង សិប្បកម្មមិនគ្រាន់តែមិនអាចពង្រីកនូវវិសាលភាពនៃការផលិតរបស់ខ្លួនបានប៉ុណ្ណោះទេ ថែមទាំងអាចប្រឈមនឹងការផ្អាកដំណើការអាជីវកម្មរបស់ខ្លួនទៀត ប្រសិនបើតម្លៃប្រេងសាំងនៅតែបន្តការឡើងថ្លៃ»។

លោក ជាម យៀប តំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃចន្ទម្សិលមិញថា ប្រទេសកម្ពុជាជាប្រទេសដែលនាំចូលប្រេងសាំង និង ឧស្ម័ន ១០០ភាគរយ ហើយបច្ចុប្បន្នប្រទេសផលិតប្រេងធំៗក្នុងពិភពលោក រួមទាំងអង្គការ OPEC ជាអ្នកធ្វើព្យុះធ្វើភ្លៀងនៅលើទីផ្សារពិភពលោក ទើបបានជាតម្លៃប្រេងមានការស្ទុះងើបមិនប្រក្រតី។ លោកបន្តថា ទោះជាបែបណា រដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាប្រមាណជាង ២០លានដុល្លារក្នុងមួយខែ ដើម្បីទប់ទល់ទៅនឹងការឡើងថ្លៃប្រេងសាំង និង ឧស្ម័ន ។ ជាមួយគ្នានេះ រដ្ឋាភិបាលបានដាក់ចេញនូវវិធានការចម្បងៗមួយចំនួនទៀតដូចជាកាត់បន្ថយពន្ធនាំចូល និង ជំរុញបន្ថែមទៀតដល់ក្រុមហ៊ុន**ឆេវរ៉ុន** Chevron ដើម្បីឲ្យពួកគេបង្កើនសកម្មភាពការងាររុករកនិងផលិតប្រេងនៅកម្ពុជា។ លោកបន្ថែមថា៖ «បញ្ហាចម្បងនៅពេលនេះ គឺមានតែការកាត់បន្ថយពន្ធនាំចូលទេ ដែលអាចជួយទប់ស្កាត់ការកើនឡើងតម្លៃប្រេងបាន»។

ប៉ុន្តែលោក វន់ ពៅ បានឲ្យដឹងថា យោងតាមរបាយការណ៍ ដែលបានដកស្រង់ចេញពីគេហទំព័រមួយរបស់ក្រុមហ៊ុន**ខាលថិកស៏** Caltex បានបង្ហាញថា រដ្ឋាភិបាលកម្ពុជាបានយកពន្ធរហូតដល់ទៅ ៣៥ភាគរយសម្រាប់ប្រេងសាំងមួយលីត្រ និង ២២ភាគរយសម្រាប់ម៉ាស៊ូតមួយលីត្រ។ លោកថ្លែងថា៖ «សំណើរបស់យើងនៅពេលនេះ គឺសុំឲ្យប្រមុខរដ្ឋាភិបាលចាត់វិធានការបញ្ចុះតម្លៃសាំងមកត្រឹម ៤០០០រៀលក្នុងមួយលីត្រ ឬ យ៉ាងហោចណាស់ មកត្រឹមស្មើនឹងប្រទេសជិតខាង»។

លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសមរង្ស៊ីបានថ្លែងថា បច្ចុប្បន្នរដ្ឋាភិបាលបានយកពន្ធប្រេងសាំងរហូតដល់ ១២០០រៀលក្នុងមួយលីត្រ ខណៈដែលប្រទេសជិតខាងមួយចំនួនគេមិនយកពន្ធប្រេង ។ លោកបន្តថា ក្រុមហ៊ុនផ្គត់ផ្គង់ប្រេងនៅកម្ពុជាក៏យកចំណេញរហូតដល់ពី ១០០០ ទៅ ១២០០រៀលក្នុង ១លីត្រផងដែរ ទើបធ្វើឲ្យប្រេងសាំងនៅកម្ពុជាមានតម្លៃខ្ពស់ជាងប្រទេសជិតខាង។ លោក យឹម សុវណ្ណ បញ្ជាក់ថា៖ «យើងអាចបញ្ចុះតម្លៃប្រេងសាំងបាន ដោយគ្រាន់តែរដ្ឋាភិបាលកាត់បន្ថយការយកពន្ធពីការនាំចូលប្រេងពី ១២០០ ឲ្យមកនៅត្រឹម ៤០០រៀលក្នុងមួយលីត្រ ហើយជំរុញឲ្យក្រុមហ៊ុនផ្គត់ ផ្គង់ប្រេងត្រូវកាត់បន្ថយប្រាក់ចំណេញរបស់ខ្លួនមកនៅត្រឹម ៥០០រៀលក្នុង ១លីត្រថែមទៀត នោះយើងអាចបញ្ចុះតម្លៃប្រេងបានទៅតាមការស្នើសុំរបស់អង្គការសង្គមស៊ីវិល និង ប្រជាពលរដ្ឋ» ៕

ដោយ យុត សុភចរិយា

ប្រភពព័ត៌មាន សារព័ត៌មានភ្នំពេញប៉ុស្តិ៍

ថ្ងៃអង្គារ ៤រោច ខែចេត្រ ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ ត្រូវនឹងថ្ងៃទី១០ ខែមេសា គ.ស.២០១២